ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តតាកែវ**

សំណុំរឿងរដ្ឋប្បវេណីលេខៈ ៨៩
ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៤
សាលក្រមរដ្ឋប្បវេណីលេខៈ **២២** (គ)
ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤

## សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃពុធ ៨កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤ ដែលមានសមាសភាពដូចតទៅ៖

**ចៅក្រម**

លោក [redacted] អនុប្រធាន និងជាចៅក្រមនៃសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តតាកែវ

**ដើមចោទ៖** ឈ្មោះ [redacted] **ចន្ធូ** ភេទស្រី កើតថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៨៥ សញ្ជាតិខ្មែរ មានទីលំ [redacted]។

ដោយមានលោក [redacted] អត្តលេខ២៨៦១T ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យក្រុមមេធាវី [redacted] និងជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ។

**ចុងចម្លើយ៖** ឈ្មោះ [redacted] **ភាន់** ភេទប្រុស កើតថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៨៦ សញ្ជាតិខ្មែរ មានទីលំនៅ [redacted]។

**អង្គហេតុ និងចំណុចវិវាទ**

**១-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ៖**

ក.សុំលែងលះជាមួយចុងចម្លើយឈ្មោះ [redacted] **ភាន់** ។

ខ.សុំសិទ្ធិអំណាចមេបាលើកូនទាំងពីរនាក់ មានឈ្មោះ [redacted] ស្រីពេជ្រ ភេទស្រី កើតថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៩ និងឈ្មោះ [redacted] បូរី ភេទប្រុស កើតថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ។

គ.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

**២-ការពន្យល់ត្រួសៗអំពីអង្គហេតុ៖**

ដើមចោទឈ្មោះ [redacted] ចន្ធូ បានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] **ភាន់** និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ លេខ២៧ នៃសៀវភៅអាពាហ៍ពិពាហ៍ លេខ០១/២០២២ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ត្រឹមត្រូវតាមច្បាប់។ អំឡុងពេលរស់នៅជាមួយគ្នាជាប្តីប្រពន្ធ ដើមចោទ ឈ្មោះ [redacted] ចន្ធូ និង ចុងចម្លើយឈ្មោះ [redacted] ភាន់ មានកូនចំនួនពីរនាក់ ឈ្មោះ [redacted] ស្រីពេជ្រ ភេទស្រី កើតថ្ងៃទី០៦ ខែមិថុនា



Scanned with CamScanner

ឆ្នាំ២០០៩ និងឈ្មោះ [redacted] បូរី ភេទប្រុស កើតថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ។ លុះដល់ឆ្នាំ២០២៣ ចុងចម្លើយឈ្មោះ [redacted] ភាន់ ចេះតែឈ្លោះប្រកែកគ្នាជាមួយដើមចោទឈ្មោះ [redacted] ចន្ទូ ជាច្រើនលើកច្រើនសារ និងបានប្រើអំពើហិង្សាមកលើរូបរាងកាយដើមចោទឈ្មោះ [redacted] ចន្ទូ ធ្វើឱ្យ ដើមចោទឈ្មោះ [redacted] ចន្ទូ អស់មនោសញ្ចេតនាក្នុងការរស់នៅជាមួយគ្នាតទៅទៀត ទើបដើមចោទឈ្មោះ [redacted] ចន្ទូ សម្រេចដាក់ពាក្យបណ្តឹងលែងលះនេះតែម្តង។

**៣-សេចក្តីថ្លែងការណ៍របស់ភាគី៖**

**៣.១ សេចក្តីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ ។**

លោក [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្ញុំបាទសុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោម៖

ក.ឱ្យដើមចោទឈ្មោះ [redacted] ចន្ទូ លែងលះជាមួយចុងចម្លើយឈ្មោះ [redacted] ភាន់ ។

ខ.សុំសិទ្ធិអំណាចមេបាលើកូនទាំងពីរនាក់ មានឈ្មោះ [redacted] ស្រីពេជ្រ ភេទស្រី កើតថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០០៩ និងឈ្មោះ [redacted] បូរី ភេទប្រុស កើតថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ។

គ.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

មូលហេតុ កូនក្តីខ្ញុំបាទជាដើមចោទឈ្មោះ [redacted] ចន្ទូ បានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយ ឈ្មោះ [redacted] ភាន់ និង បានចុះសំបុត្រអាពាហ៍ពិពាហ៍ លេខ២៧ នៃសៀវភៅអាពាហ៍ពិពាហ៍ លេខ ០១/២០២២ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ត្រឹមត្រូវតាមច្បាប់។ បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច កូនក្តីខ្ញុំបាទជាដើមចោទឈ្មោះ [redacted] ចន្ទូ និង ចុងចម្លើយឈ្មោះ [redacted] ភាន់ បានរួមរស់នៅជាមួយគ្នាមាន សេចក្តីសុខធម្មតានោះទេ អំឡុងពេលរស់នៅជាមួយគ្នាជាប្តីប្រពន្ធ ដើមចោទឈ្មោះ [redacted] ចន្ទូ និង ចុងចម្លើយឈ្មោះ [redacted] ភាន់ មានកូនចំនួនពីរនាក់ ឈ្មោះ [redacted] ស្រីពេជ្រ ភេទស្រី កើតថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៩ និងឈ្មោះ [redacted] បូរី ភេទប្រុស កើតថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ។ ក្រោយមកអំឡុងឆ្នាំ ២០២៣ ចុងចម្លើយឈ្មោះ [redacted] ភាន់ ចេះតែឈ្លោះប្រកែកគ្នាជាមួយកូនក្តីខ្ញុំបាទជាដើមចោទ ឈ្មោះ [redacted] ចន្ទូ ជាច្រើនលើកច្រើនសារ និងបានប្រើអំពើហិង្សាមកលើរូបរាងកាយកូនក្តីខ្ញុំបាទជា ដើមចោទឈ្មោះ [redacted] ចន្ទូ ធ្វើឱ្យកូនក្តីខ្ញុំបាទជាដើមចោទឈ្មោះ [redacted] ចន្ទូ អស់មនោសញ្ចេតនាក្នុងការរស់នៅជាមួយគ្នាតទៅទៀត ទើបកូនក្តីខ្ញុំបាទជាដើមចោទឈ្មោះ [redacted] ចន្ទូ សម្រេចដាក់ពាក្យបណ្តឹងលែងលះនេះតែម្តង។ កូនចំនួនពីរនាក់ មានឈ្មោះ [redacted] ស្រីពេជ្រ ភេទស្រី កើតថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៩ និងឈ្មោះ [redacted] បូរី ភេទប្រុស កើតថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ កូនក្តីខ្ញុំបាទជាដើមចោទឈ្មោះ [redacted] ចន្ទូ ជាអ្នកចិញ្ចឹមបីបាច់ថែរក្សារហូត ហេតុដូច្នេះ កូនក្តីខ្ញុំបាទជាដើមចោទឈ្មោះ [redacted] ចន្ទូ ទាមទារសិទ្ធិអំណាចមេបា ចំណែកឯ ប្រាក់ប្រដាប់ក្តី កូនក្តីខ្ញុំបាទជាដើមចោទឈ្មោះ [redacted] ចន្ទូ ជាអ្នកទទួលបន្ទុក។

**៣.២ សេចក្តីថ្លែងការណ៍របស់ចុងចម្លើយឈ្មោះ [redacted] ភាន់។** (អវត្តមាន)

**៤-ភស្តុតាង**

-សំបុត្រអាពាហ៍ពិពាហ៍ លេខ២៧ នៃសៀវភៅអាពាហ៍ពិពាហ៍ លេខ០១/២០២២ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២។

-សំបុត្របញ្ជាក់កំណើត លេខ៣៨០ នៃសៀវភៅបញ្ជាក់កំណើត លេខ០៤/២០២១ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១។



Scanned with CamScanner

-សំបុត្របញ្ជាក់កំណើត លេខ៣៨១ នៃសៀវភៅបញ្ជាក់កំណើត លេខ០៤/២០២១ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១។

-សៀវភៅស្នាក់នៅ លេខ ០០១២៨គ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២។

**៥-ចំណុចគ្មានវិវាទ និងចំណុចមានវិវាទ**

**៥.១.ចំណុចគ្មានវិវាទ-គ្មាន។**

**៥.២.ចំណុចមានវិវាទ៖**

ក.តើចុងចម្លើយឈ្មោះ [redacted] **ភាន់** ចេះតែឈ្លោះប្រកែកគ្នាជាមួយដើមចោទឈ្មោះ [redacted] **ចន្ទ** ជាច្រើនលើកច្រើនសារ និង បានប្រើអំពើហិង្សាមកលើរូបរាងកាយ ដើមចោទឈ្មោះ [redacted] **ចន្ទ** មែនឬទេ?

ខ.តើសិទ្ធិអំណាចមេបាលើកូនទាំងពីរនាក់ មានឈ្មោះ [redacted] **ស្រីពេជ្រ** ភេទស្រី កើតថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០០៩ និងឈ្មោះ [redacted] **បូរី** ភេទប្រុស កើតថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ត្រូវប្រគល់ឱ្យដើមចោទឈ្មោះ [redacted] **ចន្ទ** ឬ ចុងចម្លើយឈ្មោះ [redacted] **ភាន់** ?

## សំអាងហេតុ

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ដើមចោទ នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួចមកឃើញថា៖

១-តាមសំបុត្រអាពាហ៍ពិពាហ៍ លេខ២៧ នៃសៀវភៅអាពាហ៍ពិពាហ៍ លេខ០១/២០២២ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ របស់មន្ត្រីអត្រានុកូលដ្ឋានឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ឃើញថា ដើមចោទឈ្មោះ [redacted] **ចន្ទ** និងចុងចម្លើយឈ្មោះ [redacted] **ភាន់** គឺជាសហព័ទ្ធត្រឹមត្រូវស្របតាមច្បាប់ប្រាកដមែន និង តាមសេចក្តីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] **ចន្ទ** ថាមូលហេតុដែលកូនក្តីខ្លួនប្តឹងទាមទារលែងលះព្រោះ ចុងចម្លើយឈ្មោះ [redacted] **ភាន់** ចេះតែឈ្លោះប្រកែកគ្នាជាមួយកូនក្តីខ្លួនជាដើមចោទ ឈ្មោះ [redacted] **ចន្ទ** ជាច្រើនលើកច្រើនសារ និង បានប្រើអំពើហិង្សាមកលើរូបរាងកាយកូនក្តីខ្លួនជាដើមចោទ ឈ្មោះ [redacted] **ចន្ទ** ធ្វើឱ្យកូនក្តីខ្លួនជាដើមចោទឈ្មោះ [redacted] **ចន្ទ** អស់មនោសញ្ចេតនាក្នុងការរស់នៅជាមួយគ្នាតទៅទៀត។ តុលាការយល់ឃើញថា ការទាមទាររបស់ដើមចោទស្របតាមមាត្រា **៩៧៨** នៃក្រមរដ្ឋប្បវេណី គប្បីតុលាការទទួលស្គាល់ការទាមទារនេះ។

២-តាមសំបុត្របញ្ជាក់កំណើត លេខ៣៨០ នៃសៀវភៅបញ្ជាក់កំណើត លេខ០៤/២០២១ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០២១ និងសំបុត្របញ្ជាក់កំណើត លេខ៣៨១ នៃសៀវភៅបញ្ជាក់កំណើត លេខ០៤/២០២១ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ឃើញថា ឈ្មោះ [redacted] **ស្រីពេជ្រ** ភេទស្រី និងឈ្មោះ [redacted] **បូរី** ភេទប្រុស ជាកូនរបស់ដើមចោទឈ្មោះ [redacted] **ចន្ទ** និងចុងចម្លើយឈ្មោះ [redacted] **ភាន់** ប្រាកដមែន និងតាមសេចក្តីថ្លែងការណ៍ របស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] **ចន្ទ** ថាមូលហេតុដែលកូនក្តីខ្លួនប្តឹងទាមទារសិទ្ធិអំណាចមេបា ព្រោះកូនក្តីខ្លួនជាអ្នកចិញ្ចឹមបីបាច់ថែរក្សាកូនទាំងពីរនាក់រហូត ឃើញថាដើម្បីជាផលប្រយោជន៍កូន គប្បីតុលាការទទួលស្គាល់ការទាមទារសិទ្ធិអំណាចមេបារបស់ដើមចោទ ឈ្មោះ [redacted] **ចន្ទ** តាមមាត្រា ១០៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។

៣-ប្រាក់ប្រដាប់ក្តីដើមចោទស្នើសុំទទួលបន្ទុក គប្បីតុលាការសម្រេចតាមការស្នើសុំនេះ។



Scanned with CamScanner

## សេចក្ដីសម្រេចបញ្ចប់

១-ឱ្យដើមចោទឈ្មោះ [redacted] ចន្ទ លែងលះពីចុងចម្លើយឈ្មោះ [redacted] ភាន់ លើសំបុត្រអាពាហ៍ពិពាហ៍ លេខ២៧ នៃសៀវភៅអាពាហ៍ពិពាហ៍ លេខ០១/២០២២ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ របស់មន្ត្រីអត្រានុកូលដ្ឋានឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។

២-ប្រគល់កូន ឈ្មោះ [redacted] ស្រីពេជ្រ ភេទស្រី កើតថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៩ និងឈ្មោះ [redacted] បូរី ភេទប្រុស កើតថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ឱ្យដើមចោទឈ្មោះ [redacted] ចន្ទ ជាអ្នកមានអំណាចមេបាចំពោះចុងចម្លើយឈ្មោះ [redacted] ភាន់ ដែលគ្មានសិទ្ធិអំណាចមេបាមានសិទ្ធិចូលប្រាស្រ័យទាក់ទងកូនបាន ហើយដើមចោទឈ្មោះ [redacted] ចន្ទ ត្រូវបង្កលក្ខណៈងាយស្រួលក្នុងការចូលប្រាស្រ័យទាក់ទងនេះ។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីដើមចោទ ។

សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃពុធ ៨កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃព្រហស្បតិ៍ ៨រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤ ។

បើកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
ធ្វើនៅតាកែវ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤
**ចៅក្រម**

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ៨រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
ធ្វើនៅតាកែវ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤

**បានឃើញ**
**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner